# កិច្ចប្រជុំលើកទី១១ របស់ក្រុមប្រឹក្សាស្តង់ដាជាតិ



នៅព្រឹកថ្ងៃទី២៩ ខែឧសភា ឆ្នាំ២០១៤ នៅវិទ្យាស្ថានស្តង់ដាកម្ពុជា មានរៀបចំកិច្ចប្រជុំទី១១ របស់ក្រុមប្រឹក្សាស្តង់ដាជាតិក្រោមអធិបតីភាព ឯកឧត្តម **ចម ប្រសិទ្ធ** ទេសរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងឧស្សាហកម្ម និងសិប្បកម្ម និងជាប្រធានក្រុមប្រឹក្សាស្តង់ដាជាតិ ។

កិច្ចប្រជុំនេះ ត្រូវបានរៀបចំឡើងដោយវិទ្យាស្ថានស្តង់ដាកម្ពុជា ដែលជាលេខាធិករដ្ឋានរបស់ក្រុមប្រឹក្សាស្តង់ដាជាតិ ដើម្បីពិភាក្សាលើប្រធានបទមួយចំនួនរួមមាន:-របាយការណ៍អំពីលទ្ធផលនៃកិច្ចប្រជុំរបស់ក្រុមប្រឹក្សាស្តង់ដាជាតិលើកទី១០-បទបង្ហាញអំពីនីតិវិធីនៃការអនុម័តស្តង់ដារអន្តរជាតិ ជាស្តង់ដារជាតិ-ពិនិត្យពិភាក្សា និងអនុម័តគោលការណ៍ណែនាំ និងស្តង់ដាររបស់កូដិច និងស្តង់ដាររបស់ ISO ជាស្តង់ដារជាតិ-សំណើរសុំគោលការណ៍អនុម័តស្តង់ដារជាតិជាស្តង់ដារបញ្ជា និងបញ្ហាផ្សេងៗ ។




មានប្រសាសន៍បើកកិច្ចប្រជុំ ឯកឧត្តម ទេសរដ្ឋមន្ត្រី **ចម ប្រសិទ្ធ** ឯកឧត្តម បានចាត់ទុកកិច្ចប្រជុំក្រុមប្រឹក្សាស្តង់ដារជាតិលើកទី១១នេះ ថាជាថ្ងៃប្រវត្តិសាស្ត្រ ដែលយើងបានពិនិត្យ ពិភាក្សា និងអនុម័តលើរបៀបវីរៈសំខាន់ៗជាច្រើន ជាពិសេស គឺការអនុម័តយកស្តង់ដាកូដិចអន្តរជាតិ ជាស្តង់ដារជាតិ សម្រាប់ផលិតផលចំណីអាហារនៅកម្ពុជា ។ ឯកឧត្តម ទេសរដ្ឋមន្ត្រី បានបញ្ជាក់ថាៈបច្ចុប្បន្ននេះ វិទ្យាស្ថានស្តងដារកម្ពុជា ដែលជាលេខាធិការដ្ឋានរបស់គណៈ កម្មការបច្ចេកទេសស្តង់ដា និងក្រុមប្រឹក្សាស្តង់ដារជាតិ បាននឹងកំពុងបន្តខិតខំរៀបចំសេចក្តីព្រាងស្តង់ដារតាមវិស័យចាំបាច់នានា ដែលជាអាទិភាពសម្រាប់សេដ្ឋកិច្ចជាតិ ជាពិសេសដើម្បីចូលរួមអនុវត្តកិច្ចព្រមព្រៀងអាស៊ាន ស្តីពីការធ្វើពាណិជ្ជកម្មទំនិញ នាឆ្នាំ ២០១៥ ខាងមុខ និងកិច្ចព្រមព្រៀងរបស់អង្គការពាណិជ្ជកម្មពិភពលោក (WTO) ស្តីពីរបាំងបច្ចេកទេសចំពោះពាណិជ្ជកម្ម និងបន្តចូលរួមជាមួយរដ្ឋាភិបាល ក្នុងការការពារសុវត្ថិភាពអ្នកប្រើប្រាស់ ធានាសុខុមាលភាពសាធារណៈ បរិស្ថាន និងសម្របសម្រួលដល់ការធ្វើពាណិជ្ជកម្មជាតិ និងអន្តរជាតិ ។

តាមរយៈការពិភាក្សា ក្នុងរបៀបវីរៈទាក់ទង និងលទ្ធផលនៃកិច្ចប្រជុំរបស់ក្រុមប្រឹក្សាស្តង់ដារជាតិលើកទី១០ ដែលបានសម្រេចបង្កើតគណៈកម្មករបច្ចេកទេសចំនួន០៤ បន្ថែមលើគណៈកម្មការបច្ចេកទេសចំនួន០៦ ដែលមានស្រាប់ ឯកឧត្តម ទេសរដ្ឋមន្ត្រី និងអង្គប្រជុំបានសម្រេចកែសម្រួល និងបន្ថែមសមាសភាពមួយចំនួន មកពីក្រសួង ស្ថាប័នពាក់ព័ន្ធ និងពីវិស័យឯកជន ដើម្បីដាក់បញ្ចូលក្នុងគណៈកម្មការបច្ចេកទេសនីមួយៗ ឱ្យបំពេញកិច្ចការកាន់តែមានប្រសិទ្ធិភាព និងកាន់តែរលូន ។

ជាលទ្ធផលពិភាក្សាតាមរបៀបវីរៈនីមួយៗ គឺៈ ស្តង់ដាកូដិចចំនួន៣៣១ ដែលជាប្រភេទគោលការណ៍ណែនាំ និងជាប្រភេទស្តង់ដាផលិតផល ត្រូវបានយកមកពិនិត្យ និងសម្រេចយកជាស្តង់ដារជាតិ សម្រាប់ក្រុមហ៊ុន សហគ្រាស រោងចក្រ សិប្បកម្ម អង្គភាពធ្វើតេស្ត អង្គភាពអធិការកិច្ច និងត្រួតពិនិត្យការនាំចេញ-នាំចូលអនុវត្ត នៅក្នុងទិសដៅពង្រឹងគុណភាព និងសុវត្ថិភាពផលិតផលម្ហូបអាហារនៅកម្ពុជា ។ ស្តង់ដាអន្តរជាតិ ISO ចំនួន០៤សម្រាប់ផលិតផលបាឡែត និង

ធុងឧស្ម័នសម្ពាធទាប បានពិនិត្យ និងសម្រេចអនុម័តជាស្តង់ដារជាតិសម្រាប់ប្រើប្រាស់ជាទូទៅ ។ ស្តង់ដា ចំនួន១០ ដែលបានអនុម័តរួចជាស្តង់ដារជាតិ ត្រូវបានកំណត់ជាស្តង់ដារបញ្ជា ដើម្បីអនុវត្តជាចាំបាច់សម្រាប់ការធានាដល់សុខភាព សុវត្ថិភាព និងអាយុជីវិតរបស់អ្នកប្រើប្រាស់ ។ ផលិតផលដែលទាក់ទង និងស្តង់ដាបញ្ជាទាំងនេះរួមមានដូចជាៈ មួក សុវត្ថិភាព ផលិតផលទឹកត្រី ទឹកស៊ីអ៊ីវ ទឹកខនិជធម្មតា (ទឹកពិសារមិនេរ៉ាល់) ស៊ីម៉ង់ផតឡែនធម្មតាប្រភេទទី១ សំបក ដបប៉ូលីអេទីឡែនតេរ៉េហ្វតាឡាត (ឧ.សំបកដបទឹកពិសារ) ទឹកកកពិសារ និងមីកញ្ចប់ ។